ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៣ អនក្រ - បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

**មាត្រាតែមួយ .-**

កែសំរួលមាត្រា ២៥ មាត្រា ៤០ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៧ មាត្រា ៥១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន



Downloaded from http://www.khmerlaws.com

និងមាត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដូចខាងក្រោម ៖

**មាត្រា២៥ថ្មី ..**

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំសំបុត្រកំណើតនេះពី មេឃុំ ចៅសង្កាត់ សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរ ឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀលសំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

**មាត្រា៤០ថ្មី ..**

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែម អំពីបែបបទ នីតិវិធី នៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងករណីខាងលើនេះ ។

**មាត្រា៤៣ថ្មី ..**

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅ សាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សី ចំនួន ០២ រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវអោយខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។



Downloaded from http://www.khmerlaws.com

**មាត្រា៤៥ថ្មី ៈ**

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍-ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជន និងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

**មាត្រា៤៧ថ្មី ៈ**

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តាន ដែលនៅរស់អាចមកសុំចុះ សៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលា ឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សី ចំនួន ០២ រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា៥១ថ្មី ៈ**

ការសុំចម្លង ឬ សំរង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ហើយត្រូវបោះត្រាផង ។

**មាត្រា៥៩ថ្មីស្ទួន ៈ**

**ក.** ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៩ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។



Downloaded from http://www.khmerlaws.com

ខ.ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋ ដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានរួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុកឬម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នោះនឹងត្រូវបាន ផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

គ.ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួល ជូនប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រា-នុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់អោយមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៦ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង ស៊ូ ហោក់ស៊ី

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ ។



Downloaded from http://www.khmerlaws.com